# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៤១ MIH / ២០១៧

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ចុះថ្ងៃទី១៨ខែកុម្ភៈឆ្នាំ២០០៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខៈ៤៣៣MIH/២០១៤ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- យោងតាមការចាំបាច់របស់ក្រសួង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤

## សម្រេច

**ប្រការ១ ៖** ប្រកាសនេះ មានគោលបំណងជំរុញការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងតាមយថាប្រភេទលើរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រង ការទុកដាក់ និងការប្រើប្រាស់វត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្មដើម្បីធានាបាន នូវសុវត្ថិភាព គុណភាពសម្រាប់ការផលិត និងការប្រើប្រាស់ សំដៅធានាដល់សុខុមាលភាពសង្គម និងបរិស្ថានល្អប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ៖** វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ មាន៖

- **វត្ថុធាតុដើម** សំដៅលើវត្ថុធាតុទាំងឡាយណាដែលចាំបាច់យកមកប្រើប្រាស់ក្នុងរោងចក្រ-សិប្បកម្ម ដើម្បីផលិតបានជាផលិតផលអ្វីមួយតាមតម្រូវការ រួមមាន៖ វត្ថុធាតុដើមសំខាន់ វត្ថុធាតុដើមបន្ទាប់បន្សំ និងវត្ថុធាតុដើមជំនួយផលិតកម្ម។
- **វត្ថុធាតុដើមសំខាន់** សំដៅលើវត្ថុធាតុ ឬជាសារធាតុគោលចាំបាច់ជាមូលដ្ឋានស្នូលសម្រាប់ការផលិតបានជាផលិតផលណាមួយតាមគោលដៅដែលចង់បាន ដូចជា៖ គ្រាប់ធញ្ញជាតិ ម្សៅក្រណាត់ ជ័រកៅស៊ូ សារធាតុជ័រប្លាស្ទិក លោហៈអលោហៈ ទឹក។ល។
- **វត្ថុធាតុដើមបន្ទាប់បន្សំ** សំដៅលើវត្ថុធាតុ ឬជាសារធាតុប្រើសម្រាប់ជំនួយដល់ការផលិតបានជាផលិតផលអ្វីមួយដែលទាក់ទងទៅនឹង ពណ៌ ក្លិន រសជាតិ ភាពស្វិត ស្រួយ សោភ័ណភាព វដ្តជីវិត។ល។
- **វត្ថុធាតុដើមជំនួយផលិតកម្ម** សំដៅលើវត្ថុធាតុឬជាសារធាតុដែលតម្រូវសម្រាប់ប្រើឱ្យប្រព័ន្ធផលិតកម្មទាំងមូលដូចជា៖ ទឹក ប្រេងម៉ាស៊ីន ប្រេងកាត ប្រេងម៉ាហ្សូត សាំង ឧស្ម័ន អុស ធ្យូង អគ្គិសនី។ល។
- **គ្រោះថ្នាក់** សំដៅលើបច្ច័យអាក្រក់ទោះជារូបីយ ឬអរូបីយ ដែលកើតមានដល់មនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ដោយសារសកម្មភាពណាមួយ-វត្ថុអ្វីមួយ ការរៀបចំមិនបានសមស្រប ការធ្វេសប្រហែស ឬក៏ដោយសារគ្មានសញ្ញាណយល់ដឹង។

**ប្រការ៣ ៖** ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មមានកាតព្វកិច្ចគ្រប់គ្រងវត្ថុធាតុដើមដោយផ្ទាល់ ឬដោយចាត់តាំងអ្នកជំនាញទទួលបន្ទុកជំនួស។ ក្នុងការគ្រប់គ្រងវត្ថុធាតុដើម ត្រូវបង្កើតឲ្យមាន៖ ផែនការបញ្ជីកំណត់ត្រា ការថែទាំ ការត្រួតពិនិត្យតាមដានគុណភាព និងទុកដាក់ទិន្នន័យវត្ថុធាតុដើម។ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំត្រីមាសពីការប្រើប្រាស់វត្ថុធាតុដើមមកនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម។ បែបបទនៃការប្រើប្រាស់ កត់ត្រា ថែទាំវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម ការត្រួតពិនិត្យតាមដានគុណភាព និងទុកដាក់ទិន្នន័យត្រូវកំណត់ក្នុងសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤

**ប្រការ៤ ៖** ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវមានទីតាំងសមស្របសម្រាប់ទុកដាក់វត្ថុធាតុដើម និងបំពាក់ស្លាកសញ្ញាសម្គាល់តាមយថាប្រភេទនៃវត្ថុធាតុដើមនីមួយៗ ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយអនុលោមទៅតាមសេចក្តីណែនាំស្តីពីការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម។

**ប្រការ៥ ៖** រាល់ការរៀបចំបង្កើត ការកែលម្អ ឬផ្លាស់ប្តូរទីតាំងទុកដាក់វត្ថុធាតុដើម ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មត្រូវមានការបញ្ជាក់ពីនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦ ៖** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អាចផ្តល់លិខិតបញ្ជាក់ការនាំចូលវត្ថុធាតុដើមតាមការស្នើសុំរបស់ម្ចាស់រោងចក្រ-សិប្បកម្ម។

**ប្រការ៧ ៖** ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីមានសមត្ថកិច្ចជំនាញរបស់នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការត្រួតពិនិត្យវត្ថុធាតុដើម។

**ប្រការ៨ ៖** ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ សិប្បកម្ម និងតាមប្រកាសស្តីពីការគ្រប់គ្រងវត្ថុធាតុដើមក្នុងរោងចក្រ-សិប្បកម្ម នេះ។ ក្នុងករណីល្មើស ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

**ប្រការ៩ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គ្រប់អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត

« ដើម្បីជូនជ្រាប »

- ដូចប្រការ១០
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com